State of California-Health and Human Services Agency
Department of Health Care Services
P.O. Box 989009, West Sacramento, CA 95798-9009

XXXX XX, XXXX

16141_SFC004012D_DUP-000003-02-D

▶ SFC - SFC-999999999- ◀

John Case Sample
1234 Sample Street
Sample City CA 99999

ព័ត៌មានសំខាន់
អំពីអត្ថប្រយោជន៍ Medi-Cal របស់កូនអ្នក

សូមគោរពជូនឪពុក/ម្តាយ/អាណាព្យាបាល៖

សូមអានសំបុត្រនេះ សម្រាប់ព័ត៌មានសំខាន់អំពីអត្ថប្រយោជន៍សុខភាពរបស់កូនអ្នក ដែលមានឈ្មោះខាងក្រោមនេះ។ ដោយសារមានការផ្លាស់ប្តូរមួយ ក្នុងការធានារ៉ាប់រងសុខភាពរបស់គេ កូនអ្នកនឹងត្រូវបានចុះឈ្មោះនៅក្នុងកម្មវិធីដូចខាងក្រោមនេះ នៅកាលបរិច្ឆេទចាប់ផ្តើមដែលបានបង្ហាញ។

ឈ្មោះ	គម្រោងសុខភាព	គម្រោងធ្មេញ	កាលបរិច្ឆេទចាប់ផ្តើម៖
John Bene1 Sample	Medical Plan1	Denti-Cal	June 1, 2016
John Bene2 Sample	Medical Plan2	Denti-Cal	June 1, 2016
John Bene3 Sample	Medical Plan3	Denti-Cal	June 1, 2016
John Bene4 Sample	Medical Plan4	Denti-Cal	June 1, 2016

ការធានារ៉ាប់រងសុខភាពរបស់កូនអ្នក បានផ្លាស់ប្តូរទៅជាសេវា Medi-Cal វិសាលភាពពេញលេញ។ នេះមានន័យថា ឥឡូវនេះ កូនរបស់អ្នកមានអត្ថប្រយោជន៍កាន់តែច្រើនថែមទៀត។ វាក៏មានន័យថា កូនរបស់អ្នកនឹងទទួលការថែទាំតាមរយៈគម្រោងសុខភាពគ្រប់គ្រងការថែទាំ Medi-Cal (ហៅគម្រោងសុខភាព Medi-Cal ផងដែរ)។ ឥឡូវ ដោយកូនរបស់អ្នកមាន Medi-Cal វិសាលភាពពេញលេញ កូនរបស់អ្នកអាចបន្តទទួលការថែទាំសុខភាព ពីគ្រូពេទ្យណាដែលទទួល Medi-Cal "តម្លៃសម្រាប់សេវា" (ហៅ Medi-Cal ធម្មតាផងដែរ)។ នៅពេលដែលកូនរបស់អ្នកត្រូវបានចុះឈ្មោះក្នុងគម្រោងសុខភាព Medi-Cal មួយ គេនឹងទទួលការថែទាំតាមរយៈគម្រោងសុខភាពនោះ។

គម្រោងសុខភាព Medi-Cal ផ្តល់សេវាសុខភាព តាមរយៈបណ្តាញគ្រូពេទ្យ ដែលផ្តោតជាពិសេសទៅលើការថែទាំបឋម និងការថែទាំបង្ការជំងឺ។ នៅពេលដែលកូនអ្នកក្លាយជាសមាជិកនៃគម្រោងសុខភាព Medi-Cal មួយ គម្រោងនោះនឹងជួយគ្រប់គ្រងការថែទាំកូនអ្នក ជួយអ្នកឲ្យរកគ្រូពេទ្យ និងពេទ្យឯកទេស មានខ្សែទូរស័ព្ទដំបូន្មានពេទ្យ 24 ម៉ោង មានសេវាសមាជិកដើម្បីជួយអ្នក អាចជួយអ្នកជាមួយនឹងការដឹកជញ្ជូនទៅកាន់ការណាត់ជួបពេទ្យ និងសេវាជាច្រើនផ្សេងទៀតផង។ គម្រោងសុខភាព Medi-Cal នឹងថែមទាំងជួយអ្នក ឲ្យទទួលនូវសេវាណាដែលកូនអ្នកអាចត្រូវការ ដែលគម្រោងមិនធានារ៉ាប់រងដោយផ្ទាល់។ **កូនរបស់អ្នកនឹងក្លាយជាសមាជិកនៃគម្រោងសុខភាព Medi-Cal របស់ខោនធីអ្នក ដែលបានប្រាប់ខាងលើ មិនហួសពី 6/1/2016 ។**

កូនរបស់អ្នកនឹងថែមទាំងទទួលនូវការធានារ៉ាប់រងសុខភាពធ្មេញពីកម្មវិធីថែទាំ**ធ្មេញ**របស់ Medi-Cal ហៅថា Denti-Cal។ អ្នកអាចរកព័ត៌មានអំពីសេវាថែទាំធ្មេញ នៅក្នុងទំព័រ "សំណួរដែលគេច្រើនសួរ" ដែលភ្ជាប់ជាមួយនឹងសេចក្តីជូនដំណឹងនេះ។ កូនរបស់អ្នកនឹងត្រូវជួបគ្រូពេទ្យធ្មេញម្នាក់ ដែលទទួល Denti-Cal។ ដើម្បីរកគ្រូពេទ្យធ្មេញនៅក្បែរអ្នក សូមទូរស័ព្ទទៅ **ខ្សែទូរស័ព្ទបម្រើអតិថិជនសម្រាប់អ្នកទទួលអត្ថប្រយោជន៍ Denti-Cal តាមលេខ 1-800-322-6384 [TTY: 1-800-735-2922]**។

SFC

ទំព័រ "សំណួរដែលគេច្រើនសួរ" ដែលភ្ជាប់ជាមួយនឹងសំបុត្រនេះ មានព័ត៌មានលំអិត ស្តីពីសេវាផ្សេងៗទៀត ដែលផ្តល់ជូនតាមរយៈ Medi-Cal។ នេះមានរួមដូចជា សេវាថែទាំសុខភាពផ្លូវចិត្ត សេវាព្យាបាលបញ្ហាស្រា និងថ្នាំញៀន ការថែទាំភ្នែក និងសេវាផ្សេងៗទៀត ដែលមានលក្ខណៈចាំបាច់ខាងផ្នែកសុខភាព។

តើខ្ញុំអាចទាក់ទងទៅគម្រោងសុខភាព Medi-Cal របស់ខ្ញុំបានយ៉ាងដូចម្តេច ?

ដើម្បីទាក់ទង៖	CenCal Health
ទូរស័ព្ទទៅខ្សែទូរស័ព្ទសេវាសមាជិករបស់គេ៖	1-877-814-1861
ឬ ជួបតាមអ៊ីនធឺណិត នៅឯ៖	http://www.cencalhealth.org/members/medi-cal/

នៅពេលដែលកូនរបស់អ្នក ក្លាយជាសមាជិកនៃគម្រោងសុខភាព Medi-Cal ខាងលើនេះ អ្នកនឹងអាចជ្រើសរើសគ្រូពេទ្យម្នាក់ នៅឬក្រោយកាលបរិច្ឆេទនោះ ដោយទូរស័ព្ទទៅខ្សែទូរស័ព្ទសេវាសមាជិករបស់ពួកគេ។

បើខ្ញុំមានសំណួរបន្ថែមទៀត យ៉ាងម៉េចដែរ ?

សេវាខាងជំងឺប្រើថ្នាំញៀន៖
សម្រាប់ជំនួយជាមួយនឹងការផ្តល់ប្រឹក្សា សម្រាប់ភាពអាសន្ន សេវាបន្សាបជាតិញៀន និងការព្យាបាលក្នុងមណ្ឌលស្នាក់នៅ ឬការពិនិត្យជំងឺក្រៅរយៈពេលវែង សូមទាក់ទងកម្មវិធីក្នុងស្រុករបស់អ្នក ដោយមើលវ៉ិបសាយត៍បញ្ជីកម្មវិធីស្រាន និងថ្នាំញៀនផ្សេងៗក្នុងខោនធី៖
http://www.DHCS.ca.gov/individuals/Pages/DMC-CountyNumbersDirectory.aspx

សេវាសុខភាពផ្លូវចិត្ត៖
សម្រាប់សេវាទូទៅ ឬព័ត៌មានដែលមិនពាក់ព័ន្ធនឹងវិបត្តិ សូមទាក់ទងទៅផ្នែកសុខភាពផ្លូវចិត្តក្នុងស្រុករបស់អ្នក ដោយមើលវ៉ិបសាយត៍បញ្ជីទំនាក់ទំនងគម្រោងសុខភាពផ្លូវចិត្តក្នុងខោនធី៖
http://www.DHCS.ca.gov/individuals/Pages/MHPContactList.aspx

ខ្សែទូរស័ព្ទបម្រើអតិថិជនទទួលអត្ថប្រយោជន៍ Denti-Cal៖
សម្រាប់ជំនួយក្នុងការរកអ្នកផ្តល់សេវាថែទាំធ្មេញ Medi-Cal នៅក្នុងតំបន់របស់អ្នក ព័ត៌មានអំពីការណាត់ជួបពិនិត្យរកជំងឺ ឬសំណួរទូទៅអំពីកម្មវិធី Denti-Cal អញ្ជើញទូរស័ព្ទ ឬមើលវ៉ិបសាយត៍របស់ពួកគេ៖
1-800-322-6384 [TTY: 1-800-735-2922]
មានពីម៉ោង 8:00 a.m. ដល់ម៉ោង 5:00 p.m.
ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
http://www.denti-cal.ca.gov/WSI/Bene.jsp?fname=ProvReferral

ក្រោមច្បាប់បច្ចុប្បន្ន យើងមិនចាំបាច់ ហើយក៏មិនបញ្ចេញ ឬចែកចាយដោយវិធីណាផ្សេងទៀត នូវព័ត៌មានរបស់កូនអ្នក ជាមួយនឹងអាជ្ញាធរអន្តោប្រវេសន៍ឡើយ។

សំណួរដែលគេច្រើនសួរ អំពីការពង្រីកអត្ថប្រយោជន៍របស់កូនអ្នក នៅក្នុង Medi-Cal

1. តើ Medi-Cal គឺជាអ្វី?

Medi-Cal គឺជាឈ្មោះដែល Medicaid ត្រូវបានហៅនៅក្នុងរដ្ឋ California។ វាផ្តល់សេវាថែទាំសុខភាព ការថែទាំធ្មេញ សេវាសុខភាពផ្លូវចិត្ត ការព្យាបាលការប្រើស្រា និងថ្នាំញៀន ការថែទាំភ្នែក និងសេវាថែទាំសុខភាពចាំបាច់ផ្សេងៗ ដល់ពលរដ្ឋ California រាប់លាននាក់។ អ្នកអាចរៀនបន្ថែមអំពី Medi-Cal នៅ **www.DHCS.ca.gov**។

2. តើកូនរបស់ខ្ញុំ នៅតែត្រូវបានធានារ៉ាប់រងសុខភាព ដោយ Medi-Cal ឬទេ?

ពិតមែន កូនរបស់អ្នកនៅតែមាន Medi-Cal ប៉ុន្តែឥឡូវវាទៅជា "វិសាលភាពពេញលេញ" ហើយ។ នេះមានន័យថា ឥឡូវនេះ ការធានារ៉ាប់រងសុខភាព Medi-Cal របស់កូនអ្នក មានអត្ថប្រយោជន៍កាន់តែច្រើនថែមឡើងៗ។ កូនរបស់អ្នក នឹងទទួលអត្ថប្រយោជន៍ទាំងនេះភាគច្រើន នៅពេលដែលគេបានចូលគម្រោងសុខភាព Medi-Cal មួយ។

3. ហេតុអ្វីបានជា Medi-Cal របស់កូនខ្ញុំផ្លាស់ប្តូរ?

មានច្បាប់ថ្មីមួយនៅក្នុងរដ្ឋ California ហៅថា Senate Bill (SB) 75។ ឥឡូវនេះ កូនទាំងអស់មានអាយុក្រោម 19 ឆ្នាំ អាចទទួល Medi-Cal វិសាលភាពពេញលេញ ប្រសិនបើពួកគេបំពេញលក្ខខណ្ឌទាំងអស់។ ឥឡូវនេះ ស្ថានភាពអន្តោប្រវេសន៍របស់គេមិនបានគិតទេ។

4. ឥឡូវ តើអត្ថប្រយោជន៍ Medi-Cal របស់កូនខ្ញុំ មានអ្វីខ្លះ?

គម្រោងសុខភាព Medi-Cal របស់កូនអ្នក នឹងធានារ៉ាប់រងនូវការណាត់ជួបថែទាំសុខភាព ការចាក់ថ្នាំវ៉ាក់សាំង ថ្នាំពេទ្យ ការថែទាំភ្នែក និងការសម្រាកនៅមន្ទីរពេទ្យដោយឥតគិតថ្លៃ។ កូនរបស់អ្នកនឹងមានគ្រូពេទ្យថែទាំបឋមម្នាក់ ហើយនិងការបញ្ជូនទៅពេទ្យឯកទេស បើសិនជាគេត្រូវការ។ សម្រាប់អត្ថប្រយោជន៍ Medi-Cal បន្ថែមទៀត សូមមើលសំណួរលេខ 10។

5. តើកូនរបស់ខ្ញុំអាចផ្លាស់ប្តូរគម្រោងសុខភាព Medi-Cal បានទេ?

នៅក្នុងខោនធីដែលអ្នករស់នៅ មានគម្រោងសុខភាព Medi-Cal តែមួយទេ។ នៅពេលដែលកូនរបស់អ្នកបានទទួល Medi-Cal វិសាលភាពពេញលេញ កម្មវិធី Medi-Cal បានចាប់ផ្តើមដំណើរការចុះឈ្មោះ នៅក្នុងគម្រោងរបស់ខោនធីអ្នក។ គម្រោងនឹងមិនមានព័ត៌មានរបស់កូនអ្នកទេ លុះត្រាតែកូនបានចុះឈ្មោះសិន។ ឈ្មោះនៃគម្រោងសុខភាព Medi-Cal របស់ខោនធីអ្នក មាននៅក្នុងសំបុត្រ ដែលបានភ្ជាប់ជាមួយនឹងទំព័រ "សំណួរដែលគេច្រើនសួរ" នេះ។

6. តើខ្ញុំត្រូវបង់ថ្លៃប្រចាំខែ សម្រាប់កូនខ្ញុំដែលចូលរួម Medi-Cal ឬទេ?

ប្រសិនបើអ្នកបង់ថ្លៃប្រចាំខែឥឡូវនេះ អ្នកនឹងបន្តបង់ថ្លៃប្រចាំខែនោះ។ មិនមានអ្វីផ្លាស់ប្តូរទេ។

7. តើខ្ញុំនឹងបង់ថ្លៃរួម សម្រាប់កូនខ្ញុំដែលចូលរួម Medi-Cal ឬទេ?

មិនមានការបង់ថ្លៃរួមទេ។ គម្រោងសុខភាព Medi-Cal ធានារ៉ាប់រងថ្លៃថែទាំសុខភាពទាំងអស់ សម្រាប់កូនអ្នក។ ប្រសិនបើអ្នកបង់ "ចំណែកថ្លៃ" សព្វថ្ងៃនេះ អ្នកនឹងបន្តបង់ចំណែកថ្លៃ។

8. តើអ្នកណានឹងធ្វើជាគ្រូពេទ្យរបស់កូនខ្ញុំ នៅក្នុងកម្មវិធី Medi-Cal?

មិនទៀងទេ។ ប្រសិនបើគ្រូពេទ្យបច្ចុប្បន្នរបស់កូនអ្នក ចូលរួមចំណែកជាមួយគម្រោងសុខភាព Medi-Cal នៅក្នុងខោនធីរបស់អ្នក ប្រហែលអ្នកអាចបន្តជួបគ្រូពេទ្យនោះបាន។ ប្រសិនបើគ្រូពេទ្យមិនចូលរួមជាមួយគម្រោងសុខភាព Medi-Cal នោះទេ អ្នកនឹងត្រូវជ្រើសរើសគ្រូពេទ្យថ្មីម្នាក់ទៀត។ គម្រោងសុខភាព Medi-Cal នឹងផ្ញើទៅគ្រួសារអ្នក នូវបញ្ជីអ្នកផ្តល់សេវាមួយច្បាប់ ដើម្បីជួយអ្នកក្នុងការជ្រើសរើសគ្រូពេទ្យម្នាក់។ អ្នកតំណាងបម្រើអតិថិជន នៃគម្រោងសុខភាព Medi-Cal អាចឆែកមើលថា តើគ្រូពេទ្យណាម្នាក់ក្នុងគម្រោង មានទំនេរឬទេ។ បើអ្នកមិនជ្រើសរើសគ្រូពេទ្យទេ គម្រោងសុខភាព Medi-Cal នឹងជ្រើសរើសគ្រូពេទ្យម្នាក់សម្រាប់កូនរបស់អ្នក។ ប្រសិនបើកូនរបស់អ្នកជួបគ្រូពេទ្យម្នាក់សព្វថ្ងៃនេះ សួរគ្រូពេទ្យរបស់គេថា តើគាត់មានធ្វើការជាមួយនឹងគម្រោងសុខភាព Medi-Cal របស់កូនអ្នក ឬទេ។ បើមាន អ្នកអាចជ្រើសរើសគ្រូពេទ្យម្នាក់នោះ ក្រោយពីការចុះឈ្មោះ ហើយបន្តជួបគ្រូពេទ្យនោះ។

9. បើកូនរបស់ខ្ញុំកំពុងជួបគ្រូពេទ្យម្នាក់ ដែលមិនធ្វើការជាមួយនឹងគម្រោងសុខភាព Medi-Cal នោះ តើយ៉ាងម៉េចដែរ ? តើកូនរបស់ខ្ញុំអាចបន្តជួបពេទ្យនោះ បានទេ?

ប្រសិនបើកូនរបស់អ្នកបានជួបគ្រូពេទ្យម្នាក់នៅក្នុងរយៈពេល 12 ខែកន្លងមក ហើយគ្រូពេទ្យនោះមិនធ្វើការជាមួយនឹងគម្រោងសុខភាព Medi-Cal ទេ អ្នកអាចស្នើសុំ "ការបន្តការថែទាំ"។ ការបន្តការថែទាំ មានន័យថា កូនរបស់អ្នកអាចបន្តជួបគ្រូពេទ្យបច្ចុប្បន្នរបស់គេបាន ប្រសិនបើគ្រូពេទ្យ និងគម្រោងសុខភាព Medi-Cal អាចមានការយល់ព្រមគ្នា។ បើអ្នកចង់ទទួលការបន្តការថែទាំ សូមទាក់ទងទៅអ្នកតំណាងបម្រើអតិថិជន នៃគម្រោងសុខភាព Medi-Cal ដើម្បីសុំជំនួយ។

10. តើមានអត្ថប្រយោជន៍ Medi-Cal អ្វីទៀត?

សេវាថែទាំធ្មេញ

បើកូនរបស់អ្នកត្រូវការសេវាថែទាំធ្មេញ គេមានសិទ្ធិទទួលសេវាតាមរយៈកម្មវិធីថែទាំធ្មេញ Medi-Cal ធម្មតា ហៅថា Denti-Cal។ អ្នកត្រូវឆែករកគ្រូពេទ្យធ្មេញម្នាក់ ដែលទទួល Denti-Cal។ ដើម្បីរកគ្រូពេទ្យធ្មេញម្នាក់ អ្នកអាចទូរស័ព្ទទៅខ្សែទូរស័ព្ទបម្រើអតិថិជន **Denti-Cal តាមលេខ 1-800-322-6384 [TTY: 1-800-735-2922]**, ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 8:00 a.m. ដល់ម៉ោង 5:00 p.m.។ ការហៅទូរស័ព្ទនេះ គឺមិនគិតថ្លៃទេ។ អ្នកអាចស្វែងយល់ថែមទៀត ដោយមើល **http://www.Denti-Cal.ca.gov/**។

កុំភ្លេចយកកាត Medi-Cal របស់កូនអ្នក ទៅកាន់ការណាត់ជួបពេទ្យធ្មេញរបស់គេ។

សេវាសុខភាពផ្លូវចិត្ត

បើកូនរបស់អ្នកត្រូវការសេវាសុខភាពផ្លូវចិត្ត សូមនិយាយជាមួយនឹងគម្រោងសុខភាព Medi-Cal ថ្មីរបស់អ្នក ឬគ្រូពេទ្យរបស់អ្នក។ ប្រសិនបើគម្រោងសុខភាពថ្មីរបស់អ្នក មិនផ្តល់សេវាដែលអ្នកត្រូវការ គាត់នឹងបញ្ជូនអ្នកទៅពេទ្យឯកទេសសុខភាពផ្លូវចិត្ត ឬគម្រោងសុខភាពផ្លូវចិត្ត Medi-Cal នៅក្នុងខោនធីរបស់អ្នក។

សេវាព្យាបាលស្រានិងថ្នាំញៀន

ប្រសិនបើកូនរបស់អ្នកត្រូវការសេវាព្យាបាលស្រា ឬថ្នាំញៀន គម្រោងសុខភាព Medi-Cal ថ្មីរបស់អ្នក នឹងជួយអ្នកក្នុងការរកអ្នកផ្តល់សេវាម្នាក់។

អ្នកអាចឆែកសួរគម្រោងសុខភាព Medi-Cal របស់អ្នក បើអ្នកត្រូវការសេវាថែទាំសុខភាពណាផ្សេងទៀត ដើម្បីឲ្យដឹងថា តើមានឬទេ។

11. បើកូនរបស់ខ្ញុំទទួល Medi-Cal វិសាលភាពពេញលេញ តើវានឹងប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន៍របស់គេ ឬទេ?

អត់ទេ។ ក្រោមច្បាប់បច្ចុប្បន្ន យើងមិនចាំបាច់ ហើយក៏មិនបញ្ជូន ឬចែកចាយដោយវិធីណាផ្សេងទៀត នូវព័ត៌មានរបស់កូនអ្នកជាមួយនឹងអាជ្ញាធរអន្តោប្រវេសន៍ឡើយ។

សូមមើលវ៉ិបសាយត៍ DHCS ដូចតទៅនេះ សម្រាប់ព័ត៌មានបន្ថែមទៀត ស្តីអំពីការផ្លាស់ប្តូរមកពី SB 75៖
http://www.DHCS.ca.gov/services/Medi-Cal/eligibility/Pages/SB-75.aspx